# ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា

**CAMBODIA WATCHDOG COUNCIL INTERNATIONAL**

CWC-International, # Havreveien 94, 4635 Kristiansand City, Norway, Tel: +4790818257/ +4799489347/E-mail: cwci_secretariat@yahoo.com/ cwci@start.no


---

គ្រីស្ទានសាន់ ថ្ងៃទី ០៦ ខែមករា ឆ្នាំ២០១០

## សេចក្តីថ្លែងការណ៍

## ខួបថ្ងៃ៧មករា គឺជាការរំឭកនៃការចូលឈ្លានពានរបស់វៀតណាមនៅកម្ពុជា

ក្រុមអតីតយុទ្ធមិត្តរបស់ពួកខ្មែរក្រហម ត្រូវបានលើកបន្ទុបឱ្យឡើងកាន់អំណាចសារជាថ្មី ដោយរដ្ឋាភិបាលក្រុងហាណូយ ក្រោយពេលពួកគេរត់ភៀសខ្លួនទៅពឹងពាក់ប្រទេសវៀតណាម ដើម្បីផ្តួលរំលំរបបខ្មែរក្រហមគ្នាឯងដោយជោគជ័យ នៅថ្ងៃ ០៧ ខែមករា ឆ្នាំ១៩៧៩។ លោក ហ៊ុន សែន លោក ហេង សំរិន លោក ជា ស៊ីម និងអតីតសមមិត្តរបស់ពួកខ្មែរក្រហមជាច្រើនទៀត ដែលមានចំណេះដឹងមូលដ្ឋានបន្តិចបន្តួច បានក្លាយជាមេដឹកនាំដ៏កំពូលៗរបស់កម្ពុជា ស្ថិតនៅក្រោមខ្សែញាក់ បម្រើមហិច្ឆិតានយោបាយ និងត្រូវដឹងគុណវៀតណាមជាដរាបផង។ ជាមួយគ្នានេះប្រទេសវៀតណាម បានកត់សម្គាល់ក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន ថាថ្ងៃ ០៧ មករា ឆ្នាំ១៩៧៩ គឺជាថ្ងៃជោគជ័យយ៉ាងធំធេង ក្នុងយុទ្ធសាស្ត្រឈ្លានពានប្រទេសកម្ពុជា។

ដោយសមិទ្ធផលថ្ងៃ ០៧ ខែមករា ឆ្នាំ១៩៧៩ វៀតណាមបានដាក់កងទ័ពរបស់ខ្លួន ឈ្លានពានកម្ពុជារយៈពេល ១០ឆ្នាំ (១៩៧៩-១៩៨៩) បានចូលរួមកាប់បំផ្លាញព្រៃឈើ និងប្រមូលយកភោគផលធម្មជាតិជាច្រើនទៀតពីប្រទេសកម្ពុជា។ ជាងនេះទៀត វៀតណាមបានបង្ខំឱ្យកម្ពុជា ដែលស្ថិតនៅក្រោមអាយ៉ងខ្លួនជាអ្នកដឹកនាំ ទទួលយកការចុះកិច្ចព្រមព្រៀងលើសន្ធិសញ្ញាខុសច្បាប់មួយចំនួន ស្តីពីព្រំដែនគោក ព្រំដែនសមុទ្រ (សន្ធិសញ្ញាឆ្នាំ១៩៨២ ឆ្នាំ១៩៨៣ ឆ្នាំ១៩៨៥) និងការផ្តល់សិទ្ធិឱ្យពលរដ្ឋវៀតណាមខុសច្បាប់រស់នៅកម្ពុជា (តាមសន្ធិសញ្ញា ថ្ងៃទី១៨ កុម្ភៈ ឆ្នាំ១៩៧៩)។

ដោយផ្អែកលើសន្ធិសញ្ញាខុសច្បាប់ទាំងនេះ លោក ហ៊ុន សែន និងរដ្ឋាភិបាលរបស់លោក រួមទាំងរដ្ឋសភាជាតិ ព្រឹទ្ធសភា និងព្រះមហាក្សត្រ បានទទួលស្គាល់លើសន្ធិសញ្ញាបំពេញបន្ថែមខុសច្បាប់ថ្មីមួយទៀត នៅខែតុលា ឆ្នាំ២០០៥ ស្តីពីការកំណត់ និងការបោះបង្គោលព្រំដែនរវាងកម្ពុជា-វៀតណាម។

លទ្ធផលនៃការសងគុណថ្ងៃ ០៧ មករា យ៉ាងងងឹតងងល់របស់លោក ហ៊ុន សែន និងក្រុមមេដឹកនាំគណបក្សប្រជាជនកម្ពុជា បានអនុញ្ញាតឱ្យជនអន្តោប្រវេសន៏វៀតណាមខុសច្បាប់ប្រមាណជាង ៤ លាននាក់ បន្តរស់នៅប្រទេសកម្ពុជា ដើម្បីដណ្តើមការងារពីពលរដ្ឋខ្មែរ បំផ្លាញមច្ឆាជាតិ និងបង្កបទល្មើសនានាក្នុងសង្គម។ ម្យ៉ាងទៀតតាមរយៈការចុះសនិសញ្ញាខុសច្បាប់ទាំងនោះ បានធ្វើឱ្យកម្ពុជាបាត់បង់ព្រំដែនគោកចន្លោះពី ៤០០០ ទៅ ៦០០០ គីឡូម៉ែត្រក្រឡា និងបាត់បង់ព្រំដែនសមុទ្រប្រមាណ ៣០.០០០ គីឡូម៉ែត្រក្រឡា ទៅប្រទេសវៀតណាម។

ជាក់ស្តែងថ្មីៗនេះ ប្រជាពលរដ្ឋខ្មែរដែលរស់នៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម ជាពិសេសនៅខេត្តស្វាយរៀង បានធ្វើការ តវ៉ាដោយការបាត់បង់ដីស្រែចំការរបស់ខ្លួន ហើយពួកគាត់ និងមានការចូលរួមពីមេដឹកនាំគណបក្ស សម រង្ស៊ី ផង

បានដកបង្គោលតម្រុយព្រំដែនពីដីស្រែរបស់ពួកគាត់ចេញ កាលពីថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០០៩។ បន្ទិចក្រោយមករដ្ឋសភាកម្ពុជាបានដកអភ័យឯកសិទ្ធិលោក សម រង្ស៊ី ពីតំណាងរាស្ត្រ ហើយរដ្ឋាភិបាល បានចេញដីកាចោទប្រកាន់រូបលោកជាផ្លូវការ។ ចំណែកឯប្រជាពលរដ្ឋពីររូបទៀត ដែលជាម្ចាស់ដីស្រែ ត្រូវបានតុលាការកាត់ទោសឱ្យជាប់គុក។ ទង្វើរបស់រដ្ឋាភិបាលកម្ពុជាក្នុងករណីនេះ គឺកំពុងតែផ្គាប់ចិត្តក្នុងនាមដូចជាយ៉ង និងបន្ទបម្រើមហិច្ឆិតានយោបាយឱ្យប្រទេសវៀតណាម។

ដោយហេតុនេះ ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា សូមថ្កោលទោសជាដាច់ខាតចំពោះជនណា ដែលព្យាយាមធ្វើប្រជាភិថុតិលើប្រជាពលរដ្ឋខ្មែរ ឱ្យទទួលស្គាល់ថ្ងៃ ០៧ មករា ឆ្នាំ១៩៧៩ ជាថ្ងៃកំណើតទី២នោះ។ យើងមិនទទួលស្គាល់ជាដាច់ខាត ចំពោះការចាត់ទុកថ្ងៃទី ០៧ មករា ជាថ្ងៃឈប់សម្រាកទិវាបុណ្យជាតិ និងជាថ្ងៃខួប ដែលប្រជាពលរដ្ឋខ្មែរត្រូវដឹងគុណប្រទេសវៀតណាមឡើយ។

**ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា**

**ប្រធាន**

**ម៉ែន ណាត**